**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ០២ . សរណន

# សារាចរណែនាំ
## ស្តីពីវិធានការធានាស្ថេរភាព បរិមាណម្ហូបអាហារនៅលើទីផ្សារ និងការនាំចេញស្រូវ-អង្ករ ទៅក្រៅប្រទេស

កន្លងមក វិបត្តិហិរញ្ញវត្ថុសកលលោក បានជះឥទ្ធិពលមកលើថ្លៃទំនិញនៅលើទីផ្សារសកលលោក និងបង្កឱ្យមានអស្ថេរភាពដល់ផលិតកម្មស្បៀងអាហារ និងជីវភាពរស់នៅរបស់ប្រជាជននៅបណ្តាប្រទេសក្រីក្រ ដែលរួមមានទាំងកម្ពុជាផងដែរ។ ដើម្បីបង្កើនតម្លៃបន្ថែមដល់ការផលិត-កែច្នៃស្បៀងអាហារក្នុងស្រុក ធានាសុវត្ថិភាពស្បៀងអាហារ និងលើកទឹកចិត្តដល់កសិករ ក្នុងការនាំចេញអង្ករ-ស្រូវទៅក្រៅប្រទេស រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការដូចខាងក្រោម :

១.- ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) ពិនិត្យ និងរៀបចំសម្រួលកាត់បន្ថយនីតិវិធីសម្រាប់ការនាំចេញអង្ករឱ្យបានជាអតិបរមា ដោយធ្វើយ៉ាងណាឱ្យការនាំចេញអង្ករប្រព្រឹត្តិទៅដោយសេរី និងរលូន។

២.- ក្រសួងពាណិជ្ជកម្ម គម្បីសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការគ្រប់គ្រងការនាំចេញស្រូវទៅក្រៅប្រទេសឱ្យបានល្អ ដោយអនុញ្ញាតឱ្យក្រុមហ៊ុន សមាគមន៍ ឬកសិករអាចនាំចេញជាលក្ខណៈគ្រួសារ ក្នុងបរិមាណយ៉ាងច្រើនបំផុត ២០០តោន ក្នុងមួយថ្ងៃ ឬ ១៤០០តោន ក្នុងមួយសប្តាហ៍ ក្នុងមួយក្រុមហ៊ុន ដោយពុំចាំបាច់សុំការអនុញ្ញាតនាំចេញឡើយ។ ក្នុងករណីមានតម្រូវការនាំចេញលើសពីនេះ ក្រុមហ៊ុននាំចេញត្រូវសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម តាមរយៈក្រុមហ៊ុន ហ្គ្រីនត្រេត (Green Trade) ។

៣.- អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់មន្ត្រីឱ្យកត់ត្រាបរិមាណ និងប្រភេទស្រូវ-អង្ករ នាំចេញ-នាំចូលតាមច្រកព្រំដែនផ្លូវការ ឱ្យបានច្បាស់លាស់ ហើយរាយការណ៍មកសាមីប្រធានស្ថាប័នជារៀងរាល់ខែ។

៤.- អាជ្ញាធរដែនដី និងអគ្គស្នងការនគរបាលជាតិ ត្រូវមានវិធានការទប់ស្កាត់ រាល់ការនាំចេញស្បៀងតាមរបៀបលួចលាក់ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង (តាមករណីពាក់ព័ន្ធ) ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទការល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ